01658459

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

D266/24 & D267/32

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី*
*ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម*
*ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ៣៥)

<u>**អង្គបុរេជំនុំជម្រះ**</u>

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ជាប្រធាន**
**ចៅក្រម Olivier BEAUVALLET**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Kang Jin BAIK**
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២០

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 03 / 11 / 2020
ម៉ោង (Time/Heure) : 13:43
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

**សាធារណៈ:**

**សេចក្តីសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២**

---

<u>**សហព្រះរាជអាជ្ញា:**</u>
ជា លាង
Brenda J. HOLLIS

<u>**សហមេធាវីការពារក្តី មាស មុត ÷**</u>
អាង ឧត្តម
Michael G. KARNAVAS

<u>**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**</u>

ហុង គឹមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ
Philippe CANONNE
Laure DESFORGES
Ferdinand DJAMMEN- NZEPA

Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២" ចុះកាលបរិច្ឆេទថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ("សំណើ")[1]។

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចេញ "ដីកាដំណោះស្រាយ" របស់គាត់ ដោយបញ្ជូន មាស មុត ទៅជំនុំជម្រះ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[2] ហើយខណៈនោះដែរសហចៅក្រមស៊ើបអង្កេតជាតិបានចេញ ("ដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត") ("ដីកាលើកលែងការចោទប្រកាន់")[3] (រួមគ្នាហៅថា "ដីកាដំណោះស្រាយ")។ ដីកាដំណោះស្រាយទាំងនេះ ត្រូវបានដាក់ដាច់ដោយឡែកពីគ្នាជាភាសាអង់គ្លេស និងភាសាខ្មែរតែប៉ុណ្ណោះ ហើយសំណៅបកប្រែដាក់តាមក្រោយ។

2. នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាជាតិបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[4] ជាភាសាខ្មែរ។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ សហមេធាវីការ

---

[1] សំណុំរឿង ០០៣ សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D266/19 និងឯកសារ D267/24 ("សំណើ(ឯកសារ D266/19 និងឯកសារ D267/24)")។

[2] សំណុំរឿង ០០៣ ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D267។

[3] សំណុំរឿង ០០៣ ដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D266។

[4] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/3 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ" របស់សហព្រះរាជអាជ្ញាជាតិ (ឯកសារ D267/3)")។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ពាក្តី មាស មុត និងសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្តឹងឧទ្ធរណ៍រៀងៗខ្លួនប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5] និងដីកាលើកលែងការចោទប្រកាន់[6] ជាភាសាអង់គ្លេស។

3. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ" ("សេចក្តីពិចារណា") របស់ខ្លួន ក្នុងសំណុំរឿង ០០៤/០២[7]។

4. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តជាតិនៃអង្គបុរេជំនុំជម្រះបានផ្សព្វផ្សាយទៅកាន់ភាគីនានា ដោយចម្លងជូនអង្គបុរេជំនុំជម្រះ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង និងប្រធានការិយាល័យរដ្ឋបាលស្តីទី និងអនុប្រធានការិយាល័យរដ្ឋបាល នូវអនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ រួមជាមួយនឹងឧបសម្ព័ន្ធដែលមានភ្ជាប់មកជាមួយ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នានានៅក្នុងអង្គបុរេជំនុំជម្រះ ចាប់តាំងពីចេញសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ នេះមក ដោយបញ្ជាក់បំភ្លឺថា អង្គបុរេជំនុំជម្រះបានចាត់វិធានការរដ្ឋបាលចាំបាច់ទាំងអស់រួចហើយក្នុងការបញ្ជូនដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) និងសំណុំរឿង ០០៤/០២ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង[8]។

---

[5] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D267/4 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ មាស មុត ឯកសារ (D267/4)")។

[6] សំណុំរឿង ០០៣ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ មាស មុត (ឯកសារ D266) ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ឯកសារ D266/2 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ (D266/2)")។

[7] សំណុំរឿងលេខ ០០៤/០២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស ("សំណុំរឿង ០០៤/០២") (អ.ប.ជ ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D359/24 និងឯកសារ D360/33 ("សំណុំរឿង ០០៤/០២ សេចក្តីពិចារណា (ឯកសារ D359/24 និងឯកសារ D360/33)។

[8] សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យរបស់ចៅក្រមអន្តរជាតិ Kang Jin BAIK និង Olivier BEAUVALLET ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/36 និងឯកសារ D360/45។



E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

01658462



5. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធានអង្គបុរេជំនុំជម្រះបានចេញអនុស្សរណៈអន្តរការិយាល័យមួយ ដោយអះអាងថា មានតែផ្នែកសេចក្តីសម្រេចជាឯកច្ឆ័ន្ទនៃសេចក្តីពិចារណាប៉ុណ្ណោះ ដែលត្រូវមានសុពលភាពអនុវត្ត[9]។

6. នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ សហមេធាវីការពារក្តី មាស មុត ("សហមេធាវី") បានដាក់សំណើ ដោយស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (i) ទទួលយកសំណើនោះ និង (ii) ផ្តល់ការបញ្ជាក់បំភ្លឺតាមការស្នើសុំ ពាក់ព័ន្ធនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ[10]។ បន្ថែមពីនេះ ពួកគេបានស្នើសុំអោយអង្គបុរេជំនុំជម្រះធ្វើការស្តាប់សវនាការដើម្បីអោយភាគីអាចធ្វើការបង្ហាញពីទស្សនៈផ្សេងៗ[11]។

7. នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២" ដោយស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលសំណើនេះថាមិនអាចទទួលយកបាន[12]។

8. នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ សហមេធាវីបានដាក់ "ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺ

---

[9] សំណុំរឿង ០០៤/២ អនុស្សរណៈអន្តរការិយាល័យ ដែលចេញដោយចៅក្រម ប្រាក់ គឹមសាន ប្រធានអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ឯកសារ D359/37 និងឯកសារ D360/46។

[10] សំណើ (ឯកសារ D266/19 និងឯកសារ D267/24)។

[11] សំណើ (D266/19 and D267/24) កថាខណ្ឌ ៤៨

[12] សំណុំរឿង ០០៣ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១៣ មេសា ឆ្នាំ២០២០ ឯកសារ D266/20 និងឯកសារ D267/25 ("ចម្លើយតប (ឯកសារ D266/20 និងឯកសារ D267/25)")។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

លើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/០២”[13]។

9. នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ អង្គជំនុំជម្រះតុលាការកំពូល បានចេញ “សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរលត់ជាធរមាននៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង” ដោយច្រានចោលបណ្តឹងសារទុក្ខជាបន្ទាន់ ដែលបានដាក់នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០[14] ទៅលើអង្គសេចក្តីនៃបណ្តឹងសាទុក្ខ និងបានបិទបញ្ចប់សំណុំរឿង ០០៤/០២[15]។

## II. សេចក្តីសន្និដ្ឋាន

10. សហមេធាវីដំបូងឡើយលើកឡើងថា សំណើនេះអាចទទួលយកបាន ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង និងយុត្តាធិការដែលជាប់ជាមួយរបស់អង្គបុរេជំនុំជម្រះ និងសិទ្ធិអំណាចជា “យុត្តាធិការចុងក្រោយបង្អស់លើដំណាក់កាលបុរេជំនុំជម្រះ” “ភារកិច្ចតាមផ្លូវតុលាការក្នុងការប្រកាស” និងអំណាចក្នុងការសម្រេចទៅលើ “បញ្ហាធំធេងនានាជាទូទៅសម្រាប់យុត្តិសាស្ត្រ និងកេរដំណែលរបស់ អ.វ.ត.ក”[16]។

[13] សំណុំរឿង ០០៣ ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺលើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងរឿងក្តី ០០៤/០២ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ឯកសារ D266/21 និងឯកសារ D267/26 (“ការឆ្លើយតប (ឯកសារ D266/21 និងឯកសារ D267/26)”)។

[14] សំណុំរឿង ០០៤/០២ បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរលត់ជាធរមាននៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២០ ឯកសារ E004/2/1 (“បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ E004/2/1)”)។

[15] សំណុំរឿង ០០៤/០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងការរលត់ជាធរមាននៃសំណុំរឿង ០០៤/០២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកសារ E004/2/1/1/2 (“សេចក្តីសម្រេចលើបណ្តឹងសាទុក្ខជាបន្ទាន់របស់តុលាការកំពូល (E004/2/1/1/2)”)។

[16] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ១-១០។



PRE-TRIAL CHAMBER · CHAMBRE PRÉLIMINAIRE · E.C.C.C · C.E.T.C

11. សហមេធាវីស្នើសុំការបញ្ជាក់បំភ្លឺពីអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបញ្ហាផ្លូវច្បាប់ ដែលកើតមានឡើងពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/០២[17]។ ពិសេសជាងនេះទៀត សហមេធាវីស្វែងរកការបញ្ជាក់បំភ្លឺពីអង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងមូលដ្ឋានផ្លូវច្បាប់ ដែលចៅក្រមរបស់អង្គបុរេជំនុំជម្រះ បានពិនិត្យមើលដាច់ដោយឡែកពីគ្នាទៅលើអង្គសេចក្តី និងផ្តល់ការគាំទ្រដល់ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត បន្ទាប់ពីប្រកាសជាឯកច្ឆ័ន្ទថា សហចៅក្រមស៊ើបអង្កេត ជាលក្ខណៈបុគ្គល និងជាលក្ខណៈរួម បានបំពេញកិច្ចខុសច្បាប់ក្នុងការចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា ដែលជាលទ្ធផលត្រូវចាត់ទុកជាមោឃៈ និងត្រូវបិទផ្លូវតវ៉ា[18]។

12. ក្នុងបរិបទនេះ សហមេធាវីបានដាក់បញ្ហាផ្លូវច្បាប់ចំនួន ១២ ដូចតទៅ (១) តើមានមូលដ្ឋានច្បាប់អ្វីខ្លះសម្រាប់ការអនុវត្តវិធាន ៧២ នៃវិធានផ្ទៃក្នុង ដែលប្រតិបត្តិសម្រាប់ដោះស្រាយការខ្វែងយោបល់គ្នារវាង ស.ច.ស ដើម្បីកំណត់ថា ការចេញដីកាដំណោះស្រាយដាច់ពីគ្នាខុសច្បាប់ ឬទេ?[19] (២) តើ អ.ប.ជ ស្រុះស្រួលគ្នាដោយរបៀបណាដើម្បីប្រកាសថា ដីកាដំណោះស្រាយទាំងនោះខុសច្បាប់ និងការត្រួតពិនិត្យឡើងវិញលើដីកាដំណោះស្រាយទាំងនោះដោយផ្អែកលើអង្គសេចក្តី?[20] (៣) តើ អ.ប.ជ បានពិចារណាដោយយោងតាមវិធាន ៧៦ (៧) នៃវិធានផ្ទៃក្នុងដែរ ឬទេ ដើម្បីកំណត់ផលវិបាកនៃការប្រកាសថា ការចេញដីកាដំណោះស្រាយខុសច្បាប់?[21] (៤) តើ អ.ប.ជ ខកខានមិនបានអនុវត្តអ្វីដែលខ្លួនពិចារណាថាជាច្បាប់ដែលអាចអនុវត្តបាន និងបានប្រើប្រាស់សិទ្ធិអំណាចរបស់ខ្លួនក្នុងការពិនិត្យឡើងវិញក្នុងនាមជាសភាស៊ើបសួរជាន់ខ្ពស់ ដោយ (១) មិនបានបង្វិលដីកាដំណោះស្រាយទៅ ស.ច.ស វិញ ជាមួយនឹងការណែនាំ ឬ (២) មិនបានពិនិត្យសំណុំរឿងឡើងវិញដោយខ្លួនឯងនោះ?[22] (៥) តើចៅក្រមនៃ អ.ប.ជ ស្រុះស្រួលគ្នារបៀបណាលើការខកខាន

[17] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ១៥-៤៨។

[18] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ១៥។

[19] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ១៧។

[20] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ១៩។

[21] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ២១។

[22] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ២៣។

មិនបានបំពេញកិច្ចការរួមគ្នាក្នុងការវាយតម្លៃទៅលើសំណុំរឿងនេះ និងការចេញសេចក្តីសម្រេចមួយ ដោយចោទប្រកាន់សន្មតពីចេតនាមិនល្អចំពោះ ស.ច.ស?[23] (៦) តើបទដ្ឋានយុត្តិធម៌ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ បានរងអន្តរាយ ឬទេ នៅពេល អ.ប.ជ អនុវត្តយុត្តាធិការបណ្តឹងឧទ្ធរណ៍របស់ពួកគាត់ និងពិនិត្យឡើងវិញលើដីកាដំណោះស្រាយដាច់ពីគ្នា កាលបើដីកាដំណោះស្រាយទាំងនោះត្រូវបានប្រកាសថាខុសច្បាប់ហើយ?[24] (៧) តើ អ.ប.ជ មានកាតព្វកិច្ចត្រូវផ្តល់សេចក្តីសម្រេចជាឯកច្ឆន្ទទៅលើអនុភាពផ្លូវច្បាប់នៃការចេញដីកាដំណោះស្រាយខុសច្បាប់ ដើម្បីធានាសច្ចភាពផ្លូវច្បាប់ដែរ ឬទេ?[25] (៨) តើសំអាងផ្លូវច្បាប់អ្វីខ្លះដែលចៅក្រមជាតិនៃ អ.ប.ជ អនុវត្តដើម្បីសបញ្ជាក់ឱ្យឃើញថាសមហេតុ និងចាំបាច់សម្រាប់ការពិនិត្យឡើងវិញរបស់ខ្លួនទៅលើដីកាដំណោះស្រាយខុសច្បាប់ និងថាតើការកំណត់របស់ អ.ប.ជ ថា នីតិវិធីដោះស្រាយការខ្វែងយោបល់គ្នា មិនអាចចៀសវាងបានពី "រចនាសម្ព័ន្ធបកស្រាយដែលស្មុគស្មាញ" អាចស្រុះស្រួលគ្នាដោយការប្រកាសថា ស.ច.ស អាច "គេចចេញ" ពីនីតិវិធីនេះតាមចិត្តចង់?[26] (៩) តើដីកាសម្រេចលើកលែងចោទប្រកាន់ អាចត្រូវបានចាត់ទុកជាមូលដ្ឋានត្រឹមត្រូវតាមច្បាប់ដោយរបៀបណាសម្រាប់ឱ្យចៅក្រមជាតិនៃ អ.ប.ជ រំលត់រឿងក្តី នៅពេលដែល អ.ប.ជ ជាឯកច្ឆន្ទបានផ្តល់ការវិភាគលម្អិតអំពីរបៀបដែល ស.ច.ស បានរំលោភបំពានលើ "មូលដ្ឋានតែមួយគត់នៃក្របខណ្ឌគតិយុត្តិនៃ អ.វ.ត.ក"?[27] (១០) តើចៅក្រមជាតិនៃ អ.ប.ជ បានងាកទៅប្រើគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនត្រូវចោទ* បន្ទាប់ពីបានអនុវត្តវិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយអនុលោមទៅតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល មែនទេ?[28] (១១) តើមូលដ្ឋានផ្លូវច្បាប់អ្វីដែលចៅក្រមអន្តរជាតិនៃ អ.ប.ជ បានប្រើដើម្បីញែកឱ្យឃើញថាផ្សេងគ្នារវាង "ការចេញ" ដីកាដំណោះស្រាយ មុនពេលបិទកិច្ចស៊ើបសួរ និងពាក្យពេចន៍នៃវិធាន ៦៧(១) នៃ

---

[23] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ២៥។

[24] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ២៧។

[25] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ២៩។

[26] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៣១។

[27] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៣៣។

[28] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៣៥។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

វិធានផ្ទៃក្នុង ដែលចែងថា ស.ច.ស "ត្រូវបញ្ចប់កិច្ចស៊ើបសួរដោយការចេញដីកាដំណោះស្រាយមួយ" និងតើស្ថានភាពដើមដែលបម្រុងទុកសម្រាប់ការខ្វែងយោបល់គ្នារវាង ស.ច.ស នៅអំឡុងពេលស៊ើបអង្កេតរបស់ពួកគេ អាចអនុវត្តដោយរបៀបណាដើម្បីដោះស្រាយចំពោះការចេញដីកាដំណោះស្រាយពីរដែលខុសច្បាប់នោះ?[29] និង (១២) តើអង្គជំនុំជម្រះសាលាដំបូង អាចទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានកំហុសនីតិវិធី និងខុសច្បាប់ដោយរបៀបណា?[30]

13. សហមេធាវីលើកឡើងថា សំណើរបស់ពួកគេធ្វើឡើងជាចាំបាច់ ដោយសារតែសច្ចភាពផ្លូវច្បាប់នឹងមិនកើតឡើងនៅក្នុងសំណុំរឿង ០០៣ ប្រសិនបើ អ.ប.ជ អនុវត្តវិធីសាស្ត្រដូចគ្នា ដូចដែលបានធ្វើនៅក្នុងសំណុំរឿង ០០៤/២[31]។ ពួកគេលើកឡើងថា សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក មាស មុត នឹងត្រូវទទួលរងផលប៉ះពាល់ ដោយសារតែគាត់មិនមានឱកាសពោលប្រាស្រ័យបញ្ហាទាំងអស់នេះ នៅពេលដែល អ.ប.ជ សម្រេចលើបណ្តឹងឧទ្ធរណ៍ខ្វែងគ្នាទៅវិញទៅមកក្នុងសំណុំរឿង ០០៣[32]។

14. ជាចុងក្រោយ សហមេធាវីលើកឡើងថា ការអនុញ្ញាតតាមសំណើនេះ គឺដើម្បីជាប្រយោជន៍យុត្តិធម៌ ព្រោះការបញ្ជាក់បំភ្លឺនឹងលើកកម្ពស់ប្រសិទ្ធភាពរបស់តុលាការ សច្ចភាពផ្លូវច្បាប់ និងតម្លាភាពដោយមិនបង្កព្យសនកម្មដល់សហព្រះរាជអាជ្ញា ឬដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែសំណើនេះនឹងជួយដល់ភាគីទាំងអស់ក្នុងការសម្រេចថាតើគួរត្រូវដាក់សារណាបន្ថែមទៀតដែរ ឬយ៉ាងណា នៅចំពោះមុខ អ.ប.ជ[33]។ ដោយផ្អែកលើមូលដ្ឋាននេះ សហមេធាវីស្នើសុំឱ្យមានសវនាការផ្ទាល់មាត់មួយដើម្បីឱ្យភាគីនានា អាចបញ្ចេញដោយពេញលេញនូវគោលជំហរប្រកបដោយសំអាងហេតុរបស់ពួកគេ [34]។

---

[29] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៣៧។

[30] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៣៩។

[31] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៤០, ៤១, ៤៤, ៤៧។

[32] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) ទំព័រ ១។

[33] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៤៨។

[34] សំណើ (ឯកសារ D266/19 និងឯកសារ D267/24) កថាខណ្ឌ ៤៨។



ECCC CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

15. ក្នុងចម្លើយតបរបស់ខ្លួន ស.ព.អ លើកឡើងថា សំណើនេះគួរត្រូវបានបដិសេធ ដោយហេតុថា មិនអាចទទួលយកបាន និងស្រដៀងគ្នានេះ សូមជំទាស់ទៅនឹងសំណើរបស់ មាស មុត ដែលស្នើឱ្យមានសវនាការផ្ទាល់មាត់[35] ព្រោះថា (១) សំណើនោះគ្មានយុត្តិកម្ម និងបង្កើតបានជាការប៉ុនប៉ងខុសច្បាប់ដើម្បីបើកការពន្យល់ឡើងវិញនៅក្នុងសំណុំរឿង ០០៣ នៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាដែលធ្វើឱ្យការដោះស្រាយលើបណ្តឹងឧទ្ធរណ៍នៅក្នុងរឿងក្តីនេះ ប្រើពេលកាន់តែច្រើន[36] និង (២) ការប៉ុនប៉ងខុសច្បាប់ដើម្បីធ្វើការអន្តរាគមន៍ក្នុងសំណុំរឿង ០០៤/២ ជាករណីដែលលោក មាស មុត គ្មានសិទ្ធិ និងក៏ជាកាលៈទេសៈមិនយុត្តិកម្មសម្រាប់គាត់[37]។

16. ពីដំបូង ស.ព.អ កត់សម្គាល់ថា សហមេធាវីបានស្នើសុំឱ្យមាន "ការបញ្ជាក់បំភ្លឺ" ដែលស្វែងរកអ្វីដែលជាធរមាននឹងអាចជា "មតិយោបល់ណែនាំ" ពី អ.ប.ជ មុនពេលធ្វើសេចក្តីសម្រេចស្តាពររបស់ខ្លួនលើសំណុំរឿង ០០៣ នេះ[38]។ ស.ព.អ លើកឡើងថា សំណើនេះបង្កើតបានជាការប៉ុនប៉ងខុសច្បាប់ដើម្បីបើកការពន្យល់ឡើងវិញនៅក្នុងសំណុំរឿង ០០៣ ព្រោះសហមេធាវីទាមទារឱ្យមានសេចក្តីសម្រេចរបស់ អ.ប.ជ ដែលប្រាសចាកពីសេចក្តីសម្រេចក្នុងសំណុំរឿង ០០៤/២ និងទាមទារឱ្យ អ.ប.ជ បញ្ជូនសំណុំរឿងទៅ ស.ច.ស ឬពិនិត្យមើលសំណុំរឿងនេះឡើងវិញដោយខ្លួនឯង។[39]

17. សហព្រះរាជអាជ្ញាអន្តរជាតិ ជាដំបូងបានលើកឡើងថា សំណើសុំមិនអាចទទួលយកបាន ហើយមានភាពយឺតយ៉ាវ[40]។ ដើម្បីជាការគាំទ្រ សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ថា ដោយពិចារណាទៅលើការមិនមានចែង នៅត្រង់បទប្បញ្ញត្តិណាមួយ ក្នុងវិធានផ្ទៃក្នុង ដែលអនុញ្ញាតឱ្យដាក់សំណើ ឬទឡ្ហីករណ៍បន្ថែម នៅដំណាក់កាលនេះក្នុងកិច្ចដំណើរការនីតិវិធី ដូចជាបន្ទាប់ពីបញ្ចប់សារណាលើបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង០០៣ បន្ទាប់ពីបញ្ចប់សវនាការផ្ទាល់មាត់ និង

---

[35] ចម្លើយតប (ឯកសារ D266/20 និងឯកសារ D267/25) កថាខណ្ឌ ១, ២, ២០។

[36] ចម្លើយតប (ឯកសារ D266/20 និងឯកសារ D267/25) កថាខណ្ឌ ១, ៩-១៦។

[37] ចម្លើយតប (ឯកសារ D266/20 និងឯកសារ D267/25) កថាខណ្ឌ ១៧-១៩។

[38] ចម្លើយតប (ឯកសារ D266/20 និងឯកសារ D267/25) កថាខណ្ឌ ៩-១០។

[39] ចម្លើយតប (ឯកសារ D266/20 និងឯកសារ D267/25) កថាខណ្ឌ ៩-១០។

[40] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ៩ ដល់១៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

បន្ទាប់ពីអង្គបុរេជំនុំជម្រះបានបញ្ចប់សម្រាកទៅការពិភាក្សាសម្រេច ចាំបាច់ត្រូវសន្មតថា អង្គបុរេជំនុំជម្រះ លែងត្រូវការជំនួយពីភាគីនានា ក្នុងការពិចារណាលើផលប៉ះពាល់ នៃសេចក្តីពិចារណាលើបណ្តឹងសាទុក្ខ សំណុំរឿង០០៣ ទៀតហើយ លើកលែងតែអង្គជំនុំជម្រះស្វែងរក សារណាពីភាគីក្នុងបញ្ហានេះ[41]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងបន្ថែមថា មិនមានបទប្បញ្ញត្តិណាមួយ នៅក្នុងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ដែលតម្រូវឲ្យមានញត្តិស្នើសុំ ការបញ្ជាក់បំភ្លឺលើសេចក្តីសម្រេចតុលាការទេ[42]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា អង្គជំនុំជម្រះអាចផ្តល់ និងបានផ្តល់ក្នុងកាលៈទេសៈមួយចំនួន និងដើម្បីប្រយោជន៍យុត្តិធម៌ ការបកស្រាយពិតប្រាកដទៅលើ សេចក្តីសម្រេចរបស់តុលាការ ដើម្បីបញ្ជាក់បំភ្លឺលើបញ្ហាគតិយុត្តិ ក្នុងបញ្ហាចំពោះមុខនោះក្តី ក៏ អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា អង្គជំនុំជម្រះនឹងមិនពិនិត្យសំណើដែល "សុំការបំភ្លឺពី [អ.ប.ជ] ទាក់ទងនឹងសំអាងហេតុ ដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចពីមុន ដែលជនត្រូវចោទមិនយល់ស្រប នឹងសេចក្តីសម្រេចនោះ" ឬ សំណើសុំការបញ្ជាក់បំភ្លឺ ក្នុងរឿងក្តីដែលជនត្រូវចោទ មិនមែនជាភាគី[43]។

18. ចំពោះសំណួរដែលបានចោទសួរ នៅក្នុងសំណើសុំនោះ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា សំណួរណាយរទាំងអស់នោះ គឺជាការជំទាស់ដោយខុសច្បាប់ ចំពោះសំអាងហេតុរបស់ចៅក្រម ដោយសារតែមេធាវីមានគោលដៅ ស្នើសុំយុត្តិកម្មទៅលើ ការសម្រេចជាក់លាក់ នៅក្នុងសំណុំរឿង០០៤/២[44] ហើយមានកំហុសឆ្គង ក្នុងការទាមទារនូវសម្លេងឯកច្ឆន្ទ នៅក្នុងអង្គបុរេជំនុំជម្រះ ដោយសារតែប្រព័ន្ធច្បាប់ អ.វ.ត.ក ទទួលស្គាល់ថា សម្លេងឯកច្ឆន្ទមិនតម្រូវចាំបាច់ ហើយអាចនឹងមិនកើតមានដែរ[45]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងបន្ថែមថា សហមេធាវីមិនបានផ្តល់ភស្តុតាង គាំទ្រដល់ការអះអាងរបស់ពួកគេដែលថា ការទទួលយកសំណើគឺជាការសម្រេចបាននូវសច្ចភាព ឬតម្លាភាពគតិយុត្តិ ដោយសារតែចន្លោះប្រហោង ឬភាពមិនប្រាកដប្រជា

[41] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១១។

[42] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១២។

[43] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១២។

[44] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៣។

[45] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៤។

គតិយុត្តិ ត្រូវបានលប់បំបាត់ដោយសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះ លើការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយពីរ និងផលប៉ះពាល់នៃការចេញខុសច្បាប់នេះ ទៅលើដីកាដំណោះស្រាយនីមួយៗ[46]។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានជំទាស់ចំពោះការអះអាង របស់សហមេធាវីដែលថា សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការប្តឹងសាទុក្ខ ប្រកបដោយប្រសិទ្ធិភាព នឹងទទួលរងផលប៉ះពាល់ ព្រោះសិទ្ធិទទួលបានការជំនុំជម្រះ ប្រកបដោយយុត្តិធម៌របស់គាត់ ត្រូវបានធានាការពារដោយឱកាស ដែលគាត់អាចទទួលបានក្នុងការលើកទឡ្ហីករណ៍ ជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ ដែលជាធាតុដ៏សំខាន់នៃបញ្ហា ដែលលើកឡើងក្នុងសំណើសុំនោះ[47]។

19. សហព្រះរាជអាជ្ញាអន្តរជាតិបានបន្ថែមថា ការអនុញ្ញាតិតាមសំណើ គឺប្រឈមនឹងហានិភ័យ ក្នុងការពន្យាពេលយ៉ាងយូរ ក្នុងការសម្រេចសេចក្តីលើសំណុំរឿង ០០៣ ដោយគិតដល់ការចង់បានរបស់សហមេធាវី ពាក់ព័ន្ធការបញ្ចូលគ្នារួម នូវសំណុំរឿង០០៣ សំណុំរឿង០០៤ និងសំណុំរឿង ០០៤/២ ហើយសំណើនេះដោយផ្ទាល់ រួមជាមួយសារណាបន្ថែម និងសំណើសុំសវនាការផ្ទាល់មាត់ គឺអាចប្រមើលមើលឃើញ នូវដំណើរការច្រំដែលគ្មានទីបញ្ចប់ការបញ្ចប់ ដោយមានដែលមានដំណាក់កាលជាច្រើន នៃការចោទប្រកាន់បន្ថែម[48]។

20. សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងជាលើកទីពីរថា សំណើសុំមិនអាចទទួលយកបាន ដោយសារតែសំណើនេះគឺជា ការព្យាយាមដោយខុសច្បាប់របស់ មាស មុត ក្នុងការធ្វើអន្តរាគមន៍ក្នុង សំណុំរឿង០០៤/២[49]។ ដើម្បីជាការគាំទ្រ សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកទឡ្ហីករណ៍ថាសំណើសុំនេះ ជាលក្ខណៈសំខាន់ គឺតម្រូវឲ្យអង្គបុរេជំនុំជម្រះ បើកឡើងវិញនូវសំណុំរឿង ០០៤/២ ដែល មាស មុត មិនមានសិទ្ធិភាពពាក់ព័ន្ធ ព្រោះគាត់មិនមែនជាភាគីនៃរឿងក្តី ហើយក៏

[46] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៤។

[47] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៥។

[48] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១០ និង ១៦។

[49] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៧ ដល់១៩។

មិនត្រូវបានអញ្ជើញឲ្យចូលរួម ក្នុងនាមជា*អ្នកមិនមែនជាភាគីនៃរឿងក្ដី*[50]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងបន្ថែមថា ដោយផ្អែកលើការសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល លើការធ្វើអន្តរាគមន៍ គឺមិនមានភាពចាំបាច់ក្នុងការអនុញ្ញាតតិឲ្យ មាស មុត ធ្វើអន្តរាគមន៍ឡើយក្នុងសំណុំរឿង ០០៤/២[51]។

21. សហព្រះរាជអាជ្ញាអន្តរជាតិ បានសង្កត់ធ្ងន់លើយុត្តិសាស្ត្រ របស់អង្គបុរេជំនុំជម្រះដែលថា អង្គជំនុំជម្រះនឹងមិនពិនិត្យដោយងាយៗទៅលើសំណើ ពីអ្នកមិនមែនជាភាគី ដែលស្នើសុំធ្វើអន្តរាគមន៍ឡើយ ដោយសារតែសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ មិនអាចអនុវត្តដោយផ្ទាល់ ទៅលើអ្នកមិនមែនជាភាគី ដែលត្រូវបានតម្រូវឲ្យលើកឡើងនូវបញ្ហាគតិយុត្តិ នៅក្នុងបរិបទនៃសំណុំរឿងផ្ទាល់របស់ពួកគេ[52]។ នៅក្នុងករណីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ឡើងវិញថា សិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ត្រូវបានធានាការពារ ហើយសច្ចភាពគតិយុត្តិ មិនត្រូវបានធ្វើឲ្យមានគ្រោះថ្នាក់នោះទេ[53]។

22. ជាចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ដោយពិចារណាទៅលើអនុស្សរណៈថ្ងៃទី១២ និងថ្ងៃទី១៦ ខែមីនា របស់ចៅក្រមជាតិ និងចៅក្រមអន្តរជាតិ នៃអង្គបុរេជំនុំជម្រះ ព្រមទាំងវិធានផ្ទៃក្នុង អ.វ.ត.ក និងយុត្តិសាស្ត្រនោះ អង្គបុរេជំនុំជម្រះលែងមានយុត្តាធិការ ទៅលើសំណុំរឿង០០៤/២ ទៀតហើយ ដោយសារតែមិនមានសេចក្ដីសម្រេច ដោយសម្លេងភាគច្រើនលើសលប់ ដើម្បីបដិសេធទៅលើដីកាសម្រេច បញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ឡើយ[54]។

---

[50] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៧។

[51] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៧។

[52] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៨។

[53] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៨។

[54] ចម្លើយតប (ឯកសារ D266/20 និង D267/25) កថាខណ្ឌ ១៩។

23. នៅក្នុងការឆ្លើយតបរបស់ខ្លួន សហមេធាវីបានលើកឡើងថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនត្រឹមតែមិនបានឆ្លើយតប ចំពោះអង្គសេចក្តីនៃសំណើប៉ុណ្ណោះទេ[55] ប៉ុន្តែមិនមានការអះអាងណាមួយរបស់គាត់ នៅក្នុងចម្លើយតប តម្រូវឱ្យអង្គបុរេជំនុំជម្រះ សម្រេចថាសំណើសុំមិនអាចទទួលយកបាន ឬបដិសេធនូវដំណោះស្រាយដែលបានស្នើសុំឡើយ[56]។

24. សហមេធាវីបានលើកទឡ្ហីករណ៍ថា ផ្ទុយពីការអះអាងដែលខុសឆ្គង និងនាំឱ្យយល់ច្រឡំ របស់សហព្រះរាជអាជ្ញាអន្តរជាតិ សំណើ (១) ស្នើសុំការបញ្ជាក់បំភ្លឺ ដោយសារតែការជាប់គាំង ផ្នែកនីតិវិធីនៅក្នុងរឿងក្តី ០០៤/២ ហើយនិងការយល់ឃើញខុសៗគ្នា របស់ភាគីនានានិងចៅក្រមនៃអង្គបុរេជំនុំជម្រះ ទៅលើសេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះ មិនមែនជាការសម្រេចសេចក្តីជាក់លាក់ឡើយ[57] (២) ស្នើសុំការបញ្ជាក់បំភ្លឺ គឺមិនមែនឃោបល់ណែនាំទេ លើបញ្ហាគតិយុត្តិ ដែលប្រសិនបើមិន "ពិចារណា" នឹងបណ្តាលឱ្យមានការជាប់គាំងមិនអាចជៀសបាន ដូចដែលបានឃើញក្នុងសំណុំរឿង ០០៤/២[58] និង (៣) ពាក់ព័ន្ធតែសំណុំរឿង ០០៣ ទេ ហើយមិនតម្រូវឱ្យមានសារណាជាលាយលក្ខណ៍អក្សរឡើយ ដូច្នេះហើយមិនបណ្តាលឱ្យមាន ដំណើរការច្រំដែលគ្មានទីបញ្ចប់នោះឡើយ[59]។

25. ចំពោះទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថាសំណើមិនអាចទទួលយកបាន នឹងយឺតយ៉ាវនោះ សហមេធាវីបានអះអាងថា (១) សំណើមិនមែនជាការប៉ុនប៉ង ដើម្បីបើកឡើងវិញនូវសារណា ក្នុងសំណុំរឿង ០០៣ ហើយសំណើត្រូវបានជំរុញ ដោយសេចក្តីពិចារណារបស់ អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/២ និងការដាក់ឯកសារជាបន្តបន្ទាប់ ដែលលេចឡើងបន្ទាប់ពី មានសារណានៅក្នុងរឿងក្តី ០០៣[60] (២) សហព្រះរាជអាជ្ញាអន្តរជាតិ ទទួលស្គាល់ថាក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក អនុញ្ញាតឱ្យមានការបញ្ជាក់បំភ្លឺ ទៅលើសេចក្តីសម្រេចតាមផ្លូវ

---

[55] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ១៣។

[56] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ១។

[57] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ២។

[58] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៣។

[59] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៤។

[60] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៥។

តុលាការ ដោយដកស្រង់នូវយុត្តិសាស្ត្ររបស់ អង្គជំនុំជម្រះតុលាការកំពូល[61] (៣) ការអានដោយសាមញ្ញទៅលើសំណើបង្ហាញថា សំណើមិនបានព្យាយាមជំទាស់ ឬឆ្លើយតបចំពោះសេចក្តីពិចារណា របស់អង្គបុរេជំនុំជម្រះឡើយ ហើយក៏មិនបានស្នើសុំ ការពិចារណាឡើងវិញរបស់អង្គជំនុំជម្រះដែរ[62] (៤) ការបញ្ជាក់បំភ្លឺទៅលើចេតនា របស់អង្គបុរេជំនុំជម្រះ ក្នុងការសម្រេចថាខុសច្បាប់ សម្រាប់ការចេញដីកាដំណោះស្រាយពីរ នឹងជួយលើកតម្កើង សច្ចភាពគតិយុត្តិ និងតម្លាភាពដែលជាផលវិបាកគតិយុត្តិ នៃការសម្រេចនោះ[63] (៥) សិទ្ធិរបស់ មាស មុត ក្នុងការប្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធិភាព នឹងទទួលរងផលប៉ះពាល់អវិជ្ជមាន ដោយសារ ការបដិសេធសំណើព្រោះការសម្រេចរបស់អង្គបុរេជំនុំជម្រះ លើការចេញដោយខុសច្បាប់ នូវដីកាដំណោះស្រាយផ្សេងគ្នា ធ្វើឱ្យបណ្តឹងឧទ្ធរណ៍របស់ មាស មុត និងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្លាយជាមោឃៈ[64] និង (៦) ការអនុញ្ញាតតាមសំណើនឹងមិនបណ្តាលឱ្យមានការពន្យារពេលច្រើនឡើយ ព្រោះអង្គបុរេជំនុំជម្រះត្រូវបានផ្តល់ព័ត៌មានពេញលេញតាមការដាក់ការឆ្លើយតបហើយអាចកំណត់កាលបរិច្ឆេទសវនាការ បានយ៉ាងឆាប់រហ័សតាមរយៈប្រព័ន្ធសោតទស្សន៍[65]។

26. ចំពោះការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងការធ្វើអន្តរាគមន៍របស់ មាស មុត នៅក្នុងសំណុំរឿង ០០៤/២ សហមេធាវីបានលើកទឡ្ហីករណ៍ថា (១) សំណើមិនបានតម្រូវឱ្យអង្គបុរេជំនុំជម្រះ បើកកិច្ចដំណើរការនីតិវិធីឡើងវិញ និងធ្វើការពិចារណាឡើងវិញ លើសេចក្តីពិចារណារបស់ខ្លួន ក្នុងសំណុំរឿង០០៤/២ ឡើយ ព្រោះសំណើគ្រាន់តែស្នើសុំ ការពន្យល់បកស្រាយអំពីសំអាងហេតុរបស់អង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ និងផលប៉ះពាល់នៃសេចក្តីសម្រេចនេះ ទៅលើសំណុំរឿង ០០៣ ប៉ុណ្ណោះ[66] និង (២) អង្គបុរេជំនុំជម្រះ នៅតែមាន

---

[61] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៦។

[62] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៧។

[63] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៨។

[64] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ៩។

[65] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ១០។

[66] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ១១។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C. ១៤

យុត្តាធិការលើសំណុំរឿង ០០៤/២ ដោយសារតែសំណុំរឿង មិនទាន់ត្រូវបានបញ្ជូន ទៅអង្គជំនុំជម្រះសាលាដំបូង[67]។

[67] ការឆ្លើយតប (ឯកសារ D266/21 និង D267/26) កថាខណ្ឌ ១២។



E.C.C.C. * C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
១៥

## III. ការពិភាក្សា

27. អង្គបុរេជំនុំជម្រះ បានទទួលបណ្ដឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា ក្នុងសំណុំរឿង០០៣[68]។ នាពេលនេះ កិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿងនេះ ត្រូវបានបិទបញ្ចប់ ហើយ អង្គបុរេជំនុំជម្រះ បានត្រួតពិនិត្យទៅលើទឡ្ហីករណ៍របស់ភាគី និងពិភាក្សាសម្រេចលើបណ្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៧ នៃវិធានផ្ទៃក្នុង។

28. នៅពេលចាប់ផ្ដើមដំបូង អង្គបុរេជំនុំជម្រះពិចារណាថា ការចេញសេចក្ដីពិចារណា ឬសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ នៅក្នុងកិច្ចដំណើរការនីតិវិធីផ្សេងគ្នាមួយ មិនមានអានុភាពដោយផ្ទាល់ទៅលើសំណុំរឿងដែលកំពុងដំណើរការឡើយ។ ទោះបីជាយ៉ាងនេះក្ដី អង្គបុរេជំនុំជម្រះមិនមែនមិនដឹង អំពីទឡ្ហីករណ៍ដែលថា សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ អាចត្រូវបានយល់ច្រលំនោះទេ។

29. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សារណារបស់សហមេធាវីដែលថា សំណើអាចទទួលយកបាន ហើយមានភាពចាំបាច់សម្រាប់ប្រយោជន៍យុត្តិធម៌ ព្រោះ "ការបញ្ជាក់បំភ្លឺនឹងលើកកម្ពស់ប្រសិទ្ធិភាពតុលាការ សច្ចភាពផ្លូវច្បាប់ និងតម្លាភាព" បន្ថែមពីលើការធានាការពារ នូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ មាស មុត[69]។

30. ក្នុងន័យនេះ អង្គបុរេជំនុំជម្រះសូមបញ្ជាក់ច្បាស់ថា ទោះបីជាក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក មិនបានប្រមើលមើលជាក់ច្បាស់ អំពីលទ្ធភាពបែបនេះក្ដី តែអង្គជំនុំជម្រះរបស់ អ.វ.ត.ក អាចផ្ដល់គោលការណ៍ណែនាំផ្លូវច្បាប់ ឬការបញ្ជាក់បំភ្លឺ លើសេចក្ដីសម្រេចរបស់តុលាការ ក្នុងករណីដែលប្រយោជន៍យុត្តិធម៌តម្រូវ[70]។ អង្គជំនុំជម្រះសូមរំឭកបន្ថែមទៀតថា អង្គជំនុំជម្រះនឹងមិន

---

[68] បណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ (ឯកសារ D267/3), បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D267/4), បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (ឯកសារ D266/2)។

[69] សំណើសុំ (ឯកសារ D266/19 និង D267/24) ទំព័រ ១។

[70] អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា "អង្គជំនុំជម្រះតុលាការកំពូលរំឭកថា "ដំណើរការប្រហាក់ប្រហែលគ្នា សម្រាប់ការបំភ្លឺ ឬការកំណត់ជាក់លាក់ស្ដីពីបញ្ហាច្បាប់ គឺមានជាទូទៅនៅកម្រិតអន្តរជាតិ [ហើយ] ផ្អែកតាមមូលដ្ឋាននេះ អង្គជំនុំជម្រះ



PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C * C.E.T.C

ទទួលយក សំណើសុំបញ្ជាក់បំភ្លឺដែល "មានគោលដៅសុំការបំភ្លឺពី [អ.ប.ជ] ទាក់ទងនឹងសំអាងហេតុ ដែលបានលើកឡើងនៅក្នុងសេចក្តីសម្រេចពីមុន ដែលជនត្រូវចោទមិនយល់ស្រប នឹងសេចក្តីសម្រេចនោះ" ព្រោះសេចក្តីសម្រេចតុលាការគឺស្ថាពរ ហើយមិនត្រូវបានពន្យល់បកស្រាយបន្ថែមទៀតឡើយ[71]។

31. ដោយពិនិត្យមើលលើសំណុំរឿង និងសំណើនៅចំពោះមុខ អង្គបុរេជំនុំជម្រះសម្រេចថា សេចក្តីពិចារណាក្នុងសំណុំរឿង០០៤/២ បានផ្តល់នូវសច្ចភាពផ្លូវច្បាប់ និងតម្លាភាពដែលបានតម្រូវសម្រាប់សេចក្តីសម្រេចរបស់តុលាការ ដែលកើតចេញអង្គជំនុំជម្រះ តាមកាលៈទេសៈជាក់លាក់នៃសំណុំរឿងនោះ។ អង្គបុរេជំនុំជម្រះសម្រេចថា ប្រសិទ្ធិភាពតុលាការតម្រូវថា កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៣ ចាំបាច់ត្រូវបន្ត ហើយសំណើសុំនឹងមិនត្រូវបានយកមកពិនិត្យសម្រេចនៅដំណាក់កាលចុងក្រោយបំផុតនេះ ក្នុងដំណាក់កាលបុរេជំនុំជម្រះឡើយ។

32. ចំពោះការធានាការពារដល់ សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ របស់ជនត្រូវចោទ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿងនេះ ត្រូវបានបកស្រាយយ៉ាងល្អិតល្អន់ ដោយសារណាជាលាយលក្ខណ៍អក្សរ[72] និងលើកជាទឡ្ហីករណ៍ផ្ទាល់មាត់ ដោយភាគីនានានៅ

---

តុលាការកំពូលពិចារណាឃើញថា នៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ អង្គជំនុំជម្រះអាចនឹងទទួលយកសំណើសុំការណែនាំខាងផ្លូវច្បាប់" សូមមើល សេចក្តីសម្រេចលើសំណើរបស់ សហព្រះរាជអាជ្ញា សុំការបញ្ជាក់បំភ្លឺ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ឯកសារ E284/2/1/2, កថាខណ្ឌ ៥ *ដកស្រង់* សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់ អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំនិងការបញ្ជាក់បំភ្លឺ ឯកសារ E138/1/10/1/5/8/2, ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ១២។

[71] សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើសុំ ឲ្យមានការបំភ្លឺអំពីសេចក្តីអះអាង របស់អង្គបុរេជំនុំជម្រះ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/4/12 កថាខណ្ឌ ៤, ៦។

[72] បណ្តឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៣ (ឯកសារ D267/3), បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ឯកសារ D267/4), បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងទៅនឹងដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត (ឯកសារ D266/2)។



E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ក្នុងអំឡុង សវនាការរយៈពេលបីថ្ងៃ[73]។ សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ តាមមាត្រា ២១ នៃវិធានផ្ទៃក្នុង ត្រូវបានធានាការពារយ៉ាងត្រឹមត្រូវ។ ជាលទ្ធផល អង្គបុរេជំនុំជម្រះសម្រេចថា ផលប្រយោជន៍យុត្តិធម៌ មិនតម្រូវឲ្យមានសំណើសុំការបញ្ជាក់បំភ្លឺឡើយ នៅក្នុងសំណុំរឿងបច្ចុប្បន្ន។

33. អង្គបុរេជំនុំជម្រះពិចារណាថា តាមពិតទៅ សំណើនេះគឺជាការទាមទារឲ្យមាន ការសម្រេចសេចក្តីស្តាពររបស់អង្គជំនុំជម្រះ នៅក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន ដែលសេចក្តីសម្រេចនេះនឹងត្រូវចេញ ក្នុងពេលវេលាសមស្របខាងមុខ។ មិនមានហេតុផលណាមួយ តម្រូវឲ្យសម្រាប់អង្គបុរេជំនុំជម្រះធ្វើការ ក្នុងការសម្រេចមុនពេល លើបញ្ហាដែលស្ថិតក្នុងវិសាលភាព នៃបណ្តឹងឧទ្ធរណ៍ដែលកំពុងដំណើរការនោះឡើយ។

34. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចថា សំណើសុំមិនអាចទទួលយកបាន។

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធ** សំណើ ដោយមិនអាចទទួលយកបាន។

**បដិសេធ** សំណើរបស់សហមេធាវីក្នុងការស្នើសុំសវនាការទាំងមូល។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

**រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២០**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Olivier BEAUVALLET** **ន៉ៃ ធុល** **Kang Jin BAIK** **ហួត វុទ្ធី**

[73] សំណុំរឿង ០០៣ ដីកាកំណត់កាលវិភាគ សម្រាប់សវនាការរបស់ អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងដីកាដំណោះស្រាយ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D266/12។